00082731

**Declassified to Public**
**06 September 2012**

1266 TS

D91/I

# សេចក្តីណែនាំ ស្តីពីការប្រើពាក្យ
# អង្គការ និងពាក្យ បក្ស

តាមការពិនិត្យកន្លងមក ឃើញថា អ្នកខ្លះ និងអង្គភាពខ្លះ មានការភាន់ច្រឡំ ក្នុងការប្រើពាក្យអង្គការ និងពាក្យ បក្ស ។ ហើយនៅកន្លែងខ្លះទៀត មានសមាសភាពអាក្រក់ និង សមាសភាពខ្មាំងបង្កប់ខ្លួនក្នុង បន្លំប្រើពាក្យអង្គការ នេះដើម្បីបោកប្រាស់ និងបំផ្លិចបំផ្លាញបក្ស និង បដិវត្តន៍ ក៏មានដែរ ។

ម្យ៉ាងទៀត បក្សយើងសង្កេតឃើញថា ប្រើពាក្យអង្គការ សំរាប់ហៅបុគ្គល មិនចំណេញ សោះ ដល់ការការពារខ្សែនយោបាយ ខ្សែសតិអារម្មណ៍ និងខ្សែចាត់តាំងរបស់បក្ស វាផ្ទុយស្រឡះ ពីខ្សែបដិវត្តសង្គមនិយម របស់បក្សយើង ពីខ្សែរកំចាត់កម្មសិទ្ធិឯកជន របស់បក្សយើង ។

អាស្រ័យហេតុនេះ គណៈមជ្ឈិមបក្ស សុំផ្ញើសេចក្តីណែនាំ ចំពោះគ្រប់មូលដ្ឋាន គ្រប់ក្រសួងមន្ទីរ និងគ្រប់អង្គភាព ដូចតទៅ :-

១.- ពាក្យអង្គការ ឬពាក្យបក្ស ប្រើតែចំពោះអង្គការចាត់តាំង មិនត្រូវប្រើសំរាប់បុគ្គលឡើយ ។

២.- ចំពោះបុគ្គល ត្រូវប្រើពាក្យថា សមមិត្ត ឈ្មោះនេះ ឬសមមិត្តតំណាងនេះនោះ ឬសមមិត្តតំណាងអង្គការ ថ្នាក់នេះ ថ្នាក់នោះ :

ឧទាហរណ៍ : សមមិត្ត តេង

ឧទាហរណ៍ : សមមិត្ត លេខា

ឧទាហរណ៍ : សមមិត្ត តំណាងអង្គការ ភូមិភាគ .....

សូមអង្គការបក្ស គ្រប់ថ្នាក់ ណែនាំ និងអប់រំអំពីបញ្ហានេះ ដើម្បីឱ្យសមមិត្ត និងមិត្តយើង ជ្រួតជ្រាប និងអនុវត្ត ឲ្យល្អ ។

ចម្លងជូន :

- គ្រប់កងពល និងវរសេនាធំ
- គ្រប់ មន្ទីរ

"ដើម្បីអនុវត្ត"

--------

ភាតរភាពបដិវត្ត កក់ក្តៅបំផុត
ថ្ងៃទី ២៤.៧.៧៧

ខៀវ

ដោយភាតរភាពបដិវត្ត កក់ក្តៅបំផុត

ថ្ងៃ ១១.៧.៧៧

គណៈ ៨៧០